# កាលៈទេសៈដែលជំរុញឱ្យព្រះកូណា សីហនុចុះហត្ថលេខាកាត់ដីកម្ពុជា ក្រោមឱ្យទៅយួន... (១៩៤៩)

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី៣១ ឧសភា ២០០៥

តាមពិតក្នុងសម័យនោះ ព្រះកូណានរោត្តម-សីហនុ ជារាជាធម្មនុញ្ញ (អាយុ២៧ឆ្នាំ)... ទ្រង់ឥតមាន«អំណាចគ្រប់ប្រភេទ»នៅក្នុងកណ្ដាប់ដៃនោះឡើយ... ទ្រង់ឥតមានសម្បូណាផ្តាសិទ្ធិរាជ (Absolutisme royal) ដូចស្តេចជ័យជេដ្ឋាទី២ ដែលបានយកដីភាគខាងកើតនិងខាងជើងព្រៃនគរ ទៅដូរជាមួយនឹងសម្រស់របស់ស្រីយួននោះឡើយ ។ ប៉ុន្តែគឺលោកយែម-សំបួរ ជនម្នាក់ដែលបានក្បត់គណបក្សប្រជាធិបតេយ្យ... ហើយដែលត្រូវព្រះកូណាតែងតាំងឲ្យធ្វើជារដ្ឋមន្ត្រីទី១បានធ្វើរដ្ឋប្រហាររំលាយរដ្ឋសភា និងបានលើកអំណាចសំបូរបែបទាំងនេះ ទៅថ្វាយទ្រង់វិញ ។

គួរជ្រាបថា នៅក្នុងសម័យនោះ ពួកយួនមិនទាន់ទាមទារឯករាជ្យពីបារាំងទេ... វារុញឲ្យខ្មែរធ្វើមុន... ដើម្បីឲ្យបារាំងស្អប់ខ្មែរ កាត់ទឹកដីកម្ពុជាក្រោមឲ្យទៅយួន ។

នៅក្នុងកាលៈទេសៈដែលវរជនខ្មែរជាច្រើន កំពុងធ្វើការទាមទារឯករាជ្យ (សឺង-ង៉ុកថាន់, ស៊ឹម-វ៉ារ, ស៊ីសុវត្ថិ-យុត្តិវង្ស, អៀវ-កើស)... យួនបានបង្ខំបារាំងឲ្យធ្វើលក្ខន្តិកៈថ្មីនៃដែនដីឥណ្ឌូចិន ដោយបង្ហាញអំពីផែនទីកម្ពុជាថ្មី ដោយគ្មានទឹកដីកម្ពុជាក្រោម ។ ក៏ប៉ុន្តែមាត្រាទី៩៦នៃរដ្ឋធម្មនុញ្ញរបស់ទ្រង់ស៊ីសុវត្ថិ-យុត្តិវង្ស (១៩៤៦) បានចែងច្បាស់ណាស់ថា «បញ្ហាអ្វីក៏ដោយ ដែលព្រះរាជាត្រូវចុះហត្ថលេខាជាមួយប្រទេសបារាំង និងជាមួយរដ្ឋដទៃទៀតនៅក្នុងក្របខណ្ឌនៃសហភាពបារាំង ត្រូវតែមានចង់ភ្ជាប់ជាមួយ នឹងការសំរេចចិត្តរបស់រដ្ឋសភាជាតិផងដែរ ដោយមានតំរូវឲ្យមានការបោះឆ្នោត ។ ក៏ប៉ុន្តែ ព្រះកូណាដឹងច្បាស់ណាស់ថា បើទ្រង់កោះហៅពួកសមាជិករដ្ឋសភាមកវិញ ពួកគេច្បាស់ជាមិនយល់ព្រមចុះហត្ថលេខាទៅលើសន្ធិសញ្ញាបារាំង-ខ្មែរ នៃឆ្នាំ១៩៤៥នោះឡើយ» ( Essai sur la Démocratie au Cambodge, par Philippe Preschez- p. 39) ។

គឺនៅក្នុងកាលៈទេសៈបែបនេះហើយ ដែលព្រះកូណានរោត្តម-សីហនុ បានចុះហត្ថលេខាកាត់ទឹកដីកម្ពុជាក្រោមទៅឲ្យយួន (ក្នុងឆ្នាំ១៩៤៩) តែម្នាក់ឯង តាមរយៈសន្ធិសញ្ញាបារាំង-ខ្មែរ ដែលចាប់ផ្តើមធ្វើឡើងតាំងពីឆ្នាំ១៩៤៥ ។ ប៉ុន្តែការចុះហត្ថលេខារបស់ស្តេចខ្មែរនេះ គឺជាទង្វើខុសច្បាប់ ពីព្រោះជាអំពើក្បត់នឹងរដ្ឋធម្មនុញ្ញ, ពីព្រោះព្រះរាជាខ្មែរជារាជាធម្មនុញ្ញ ហើយពុំមានសិទ្ធិសំរេចអំពីទឹកដីខ្មែរ ដោយគ្មានហត្ថលេខារបស់ប្រធានរដ្ឋសភា គឺលោកអៀវ-កើសនោះឡើយ ។

⌘

⌘ ⌘

## លក្ខណៈនៃរដ្ឋប្រហារក្បត់រដ្ឋធម្មនុញ្ញ របស់យ៉ែម-សំបួរ ហើយនិងនរោត្តម-សីហនុ

★ នៅខែកញ្ញា១៩៤៩... អ្នកតំណាងរាស្ត្រប្រជាធិបតេយ្យម្នាក់ បានដាក់ញត្តិដកសេចក្តីទុកចិត្តពីរដ្ឋាភិបាលយ៉ែម-សំបួរ ។ លោកយ៉ែម-សំបួរក៏បានស្នើឲ្យព្រះកូណា (នរោត្តម-សីហនុ) រំលាយរដ្ឋសភា ។ ព្រះរាជាទ្រង់បានយល់ព្រម ។ លោកប្រធានរដ្ឋសភាអៀវ-កើស ដើម្បីចៀសវាងការរំលាយរដ្ឋសភា ក៏បានដកញត្តិនេះទៅវិញ ដោយមានការបោះឆ្នោតនៅថ្ងៃទី១៧កញ្ញា១៩៤៩ ។ ក៏ប៉ុន្តែ វាយឺតពេលទៅហើយ... ព្រះកូណាបានសំរេចរួចទៅហើយ, រដ្ឋសភាត្រូវតែរំលាយចោល ។

★ រដ្ឋមន្ត្រីទី១យ៉ែម-សំបួរ ឥតមានរៀបចំធ្វើការបោះឆ្នោតសាជាថ្មីទេ ដោយសំអាងថា ប្រទេសកម្ពុជាមានអសន្តិសុខ...

★ តាមច្បាប់រដ្ឋធម្មនុញ្ញសម័យនោះ, កាលណាមានការរំលាយរដ្ឋសភារួចហើយ ព្រះកូណាត្រូវតែងតាំងលោកប្រធានរដ្ឋសភា (អៀវ-កើស) ឲ្យធ្វើជារដ្ឋមន្ត្រីទី១បណ្តោះអាសន្ន ដើម្បីរៀបចំធ្វើការបោះឆ្នោតសាជាថ្មី... ប៉ុន្តែព្រះកូណានៅតែទុកលោកយ៉ែម-សំបួរ ឲ្យធ្វើជារដ្ឋមន្ត្រីទី១ដដែល ។

★ នៅថ្ងៃទី១៤មករា១៩៥០, លោករដ្ឋមន្ត្រីទី១យ៉ែម-សំបួរ បានបញ្ជាឲ្យមេប៉ូលីស សេង-ទិព្វ បញ្ជូនមនុស្សទៅពិឃាតលោកអៀវ-កើស ដោយមានការចោលគ្រាប់បែកដៃ ទៅក្នុងការិយាល័យនៃគណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាធិបតេយ្យ ។

នៅក្នុងចំណោមព្រឹត្តិការណ៍រឹករវទាំងនេះ គ្មានប្រជាជនខ្មែរណាម្នាក់ (ក្រៅតែពីជនជាតិយួនបន្លំខ្លួនជាខ្មែរ) យល់ថា វិបត្តិនយោបាយទាំងឡាយទាំងពួងខាងលើនេះ គឺជាទង្វើថ្លិនភ្លែក ដើម្បីអនុញ្ញាតឲ្យយួនប្លន់ទឹកដីកម្ពុជាក្រោមបានដោយធម៌តែប៉ុណ្ណោះ ។៚